Monthly Report
Volume 40

April
2025

## Project Activities in April:

- 7th : Monthly Meeting with JICA HQ / Cambodia Office
- 23rd & 24th : TOT3 in BTB (Nursing Ethics & Nursing Research course)
- 23rd : Meeting with BTB PHD, RTC and PRH

## សកម្មភាពគម្រោងខែមេសា៖

- ថ្ងៃទី៧ ៖ ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្តាល JICA និង ការិយាល័យ JICA នៅប្រទេសកម្ពុជា
- ថ្ងៃទី២៣ និងទី២៤៖ TOT3 នៅខេត្តបាត់ដំបង (សីលធម៌ នៃការថែទាំ និង ការស្រាវជ្រាវផ្នែកថែទាំ)
- ថ្ងៃទី ២៣ ៖ កិច្ចប្រជុំជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបាត់ដំបង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ និងមន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង

## Discussion on INSET Implementation with BTB PHD, RTC, and PRH

## ការពិភាក្សាលើការអនុវត្តវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) ជាមួយ BTB PHD, RTC, និង PRH

On 23rd April, the project team together with Assistant Prof. Dr. Koy Virya, the chair of Training Management Team (TMT) and Deputy Director of the Department of Hospital Service, MoH, held a meeting with Directors, Deputy Directors, and other key members of the BTB PHD, RTC, and PRH to discuss the implementation plan for INSET to be conducted in BTB after the completion of TOT3. Following the project team's explanations, participants actively discussed the establishment of the Provincial Training Management Team (PTMT), budgeting options, and practical approaches for organizing the training. The discussion will resume in May.

នៅថ្ងៃទី២៣ ខែមេសា ក្រុមការងារគម្រោងរួមជាមួយនឹងលោកបណ្ឌិត កុយ វីរីយ៉ា ប្រធានក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក និងជាអនុប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល បានជួបប្រជុំជាមួយឯកឧត្តមប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបាត់ដំបង (PHD) លោកស្រីនាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង(RTC) លោកប្រធានមន្ទីរពេទ្យខេត្ត (PRH) និងមន្ត្រីក្រោមឱវាទផ្សេងទៀត ដើម្បីពិភាក្សាអំពីផែនការអនុវត្តសម្រាប់វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារដែលនឹងត្រូវធ្វើឡើងនៅក្នុងខេត្តបាត់ដំបងបន្ទាប់ពីបញ្ចប់វគ្គTOT3។ បន្ទាប់ពីការពន្យល់របស់ក្រុមការងារគម្រោង អង្គប្រជុំ បានពិភាក្សាយ៉ាងសកម្មអំពីការបង្កើតក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលក្នុងពេលបម្រើការងារថ្នាក់ខេត្ត (PTMT) ជម្រើសថវិកា និងវិធីសាស្ត្រជាក់ស្តែងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល ហើយការពិភាក្សានឹងបន្តនៅខែឧសភា។







Meeting with BTB team at BTB PHD

## TOT3 in BTB: Nursing Ethics and Nursing Research

## TOT3 នៅខេត្តបាត់ដំបង: វគ្គសីលធម៌ នៃការថែទាំ និង វគ្គការស្រាវជ្រាវផ្នែកថែទាំ

Following the four courses conducted in December and January, the project continued another round of Training of Trainers (TOT) sessions in Battambang (BTB) on 23rd and 24th April. During these two days, two courses, Nursing Ethics and Nursing Research, were conducted simultaneously. These sessions were held at BTB Regional Training Center (RTC) with the cooperation of BTB Provincial Health Department (PHD) and Provincial Referral Hospital (PRH). Trainers and participants engaged actively, and real-case discussions were included to ensure practical application. After conducting final round of TOT3 in May and demonstration practices of lectures in June, the participants are expected to be officially certified as INSET trainers.

បន្ទាប់ពីវគ្គបណ្តុះបណ្តាលចំនួនបួនដែលបានធ្វើឡើងក្នុងខែធ្នូ និងខែមករា។ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) បន្តទៀតគឺ វគ្គសីលធម៌ នៃការថែទាំ និងការស្រាវជ្រាវផ្នែកថែទាំ នៅថ្ងៃទី២៣ និងទី២៤ ខែមេសា នៅសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង (RTC)។ ក្នុងអំឡុងពេលពីរថ្ងៃនេះ វគ្គសិក្សាចំនួនពីរគឺវគ្គសីលធម៌ នៃការថែទាំ និងវគ្គការស្រាវជ្រាវផ្នែកថែទាំ ត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នា ក្រោមកិច្ចសហការ ពីមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត (PHD) និងមន្ទីរពេទ្យបង្អែកខេត្ត (PRH)។ គ្រូបង្គោល និងសិក្ខាកាមបានចូលរួមយ៉ាងសកម្ម ហើយការពិភាក្សាលើករណីជាក់ស្តែងត្រូវបានរួមបញ្ចូលផងដែរ ដើម្បីធានាឱ្យការអនុវត្តមានប្រសិទ្ធភាពពេញលេញ។ ការបង្រៀនជុំចុងក្រោយនៅខេត្តបាត់ដំបង នឹងត្រូវបានបញ្ចប់នៅខែឧសភា ហើយវគ្គការបង្រៀនសាកល្បង នឹងចាប់ផ្តើមក្នុងខែមិថុនា បន្ទាប់ពីនោះអ្នកចូលរួម(ToT3)នឹងត្រូវបានបញ្ជាក់ជាផ្លូវការថាជាគ្រូវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET)។



Opening session



## UPCOMING ACTIVITIES IN MAY

- 7th & 8th: TOT3 in BTB (Communication & Nursing Informatics)
- 8th: Meeting with HRDD, BTB PHD, RTC & PRH
- 12th : Monthly Meeting with JICA HQ / Cambodia Office
- 21st-22nd & 28th-29th : TOT3 in KCM (Basic Nursing Skill & Nursing management & Leadership, Nursing Process Application & QI & Patient Safety)

- ថ្ងៃទី៧ និង ទី៨ ៖ វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ខេត្តបាត់ដំបង) - ការប្រាស្រ័យទាក់ទង និងវគ្គព័ត៌មានវិទ្យា នៃការថែទាំ
- ថ្ងៃទី៨: កិច្ចប្រជុំជាមួយ HRDD, BTB PHD, RTC & PRH
- ថ្ងៃទី១២ ៖ កិច្ចប្រជុំប្រចាំខែជាមួយការិយាល័យកណ្តាល JICA/ការិយាល័យកម្ពុជា
- ថ្ងៃទី២១ ដល់ទី២២ និងទី២៨ ដល់ទី ២៩៖ វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ខេត្តកំពង់ចាម)
  -វគ្គជំនាញមូលដ្ឋាន នៃការថែទាំ, ការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ,
  -វគ្គការប្រើប្រាស់ដំណើរការ នៃការថែទាំ និងវគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ

## CONTACT INFORMATION

**Email:** info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

Scan here to find out more about us:

JICA's FB Page

Project's Homepage